# សេចក្តីថ្លែងការណ៍រួម

## ក្នុងឱកាសនៃទិវាសិទ្ធិមនុស្ស អង្គការសង្គមស៊ីវិលសូមអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជាគោរពកាតព្វកិច្ចសិទ្ធិមនុស្ស

*រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០*

នៅក្នុងឱកាសនៃទិវាសិទ្ធិមនុស្ស យើងខ្ញុំជាអង្គការសង្គមស៊ីវិលចំនួន៦៩ ដូចរាយនាមខាងក្រោម សូមអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជា («រដ្ឋាភិបាល») គោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា («រដ្ឋធម្មនុញ្ញ») ព្រមទាំងបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន។ យើងខ្ញុំក៏សូមអំពាវនាវឲ្យរដ្ឋាភិបាលបញ្ឈប់ជាបន្ទាន់នូវការកំណត់មុខសញ្ញាទៅលើសកម្មជន អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន អ្នកគាំទ្រគណបក្សជំទាស់និងសំឡេងរិះគន់ដទៃទៀតផងដែរ ដែលប្រការនេះបានធ្វើឱ្យស្ថានភាពសិទ្ធិមនុស្សកាន់តែមានភាពអាប់អួរខ្លាំងនៅក្នុងឆ្នាំ២០២០ ព្រមទាំងសូមឲ្យដោះលែងសកម្មជន អ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន ដែលត្រូវបានឃុំខ្លួនទាំងអស់ដោយគ្មានលក្ខខណ្ឌ។

សម្រាប់កម្ពុជា ឆ្នាំនេះគឺជាខួបគម្រប់ ២៧ ឆ្នាំនៃទិវាសិទ្ធិមនុស្ស ដែលទិវានេះត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំនៅទូទាំងពិភពលោកដើម្បីរំឭកដល់ការអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ ឆ្នាំនេះគឺជាលើកដំបូងដែលទិវាសិទ្ធិមនុស្សនៅកម្ពុជានេះមិនមែនជាថ្ងៃឈប់សម្រាកនៅកម្ពុជាទៀតទេ។ ការដកថ្ងៃឈប់សម្រាកនេះគឺជាសញ្ញាមួយបង្ហាញពីកង្វះឆន្ទៈរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិមនុស្ស និងស្របពេលមានដែលមានការកើនឡើងនូវការបង្ក្រាបសិទ្ធិមនុស្ស សេរីភាពមូលដ្ឋាន និងលទ្ធិប្រជាធិបយតេ្យនៅកម្ពុជាផងដែរ។

ការវិវឌ្ឍច្បាប់ដែលគួរឱ្យព្រួយបារម្ភមួយចំនួននៅក្នុងឆ្នាំនេះ ធ្វើឡើងក្នុងគោលបំណងកាត់បន្ថយបន្តិចម្តងៗនូវការអនុវត្តសេរីភាពរបស់ប្រជាពលរដ្ឋទាំងនៅលើ និងក្រៅបណ្តាញអ៊ីនធឺណិត។ ក្នុងនោះរួមមាន *ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន* ត្រូវបានប្រកាសឱ្យអនុវត្តក្នុងខែមេសា ដែលផ្តល់អំណាចដល់រដ្ឋាភិបាលក្នុងការរឹតត្បិតការអនុវត្តសេរីភាពមូលដ្ឋានរបស់សាធារណជន ដោយពុំមានការកំណត់ក្នុងគ្រាប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។ បន្ថែមលើនេះ ការធ្វើវិសោធនកម្មមាត្រាមួយចំនួននៃច្បាប់ស្តីពីសហជីពនៅក្នុងខែមករា ពុំបានដោះស្រាយនូវភាពចន្លោះប្រហោងនៃច្បាប់ឡើយ ដែលនាំឱ្យច្បាប់នោះនៅតែរឹតត្បិតធ្ងន់ធ្ងរលើលទ្ធភាពរបស់កម្មករនិយោជិតក្នុងការចូលជាសមាជិក និងបង្កើតសហជីព។ លើសពីនេះទៀត សេចក្តីព្រាងច្បាប់ និងអនុក្រឹត្យចំនួន ៣ នឹងធ្វើឱ្យប៉ះពាល់ថែមទៀតលើសិទ្ធិមនុស្ស គឺ *ច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ* *សេចក្តីព្រាងអនុក្រឹត្យស្តីអំពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ* និង *សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យា*។ ប្រសិនបើត្រូវបានអនុម័ត ច្បាប់និងអនុក្រឹត្យនេះនឹងដាក់ទោសព្រហ្មទណ្ឌលើសកម្មភាពប្រចាំថ្ងៃរបស់សាធារណជនទាំងនៅក្នុងនិងក្រៅបណ្តាញអ៊ីនធឺណិតដោយអនុញ្ញាតឱ្យមានការគ្រប់គ្រងទៅលើជម្រើស

នៃការស្លៀកពាក់ ការផ្តល់សិទ្ធិឱ្យមានការឃ្លាំមើលមហាជន និងការចាប់ពិរុទ្ធលើប្រព័ន្ធអ៊ីនធឺណិតជាដើម ដែលប្រការនេះនឹងធ្វើឱ្យធ្លាក់ចុះខ្លាំងនូវសេរីភាពមូលដ្ឋាន។

បន្ថែមលើការវិវឌ្ឍផ្នែកច្បាប់នេះ ឆ្នាំ២០២០ ក៏បានបង្ហាញនូវការរំលោភបំពានធ្ងន់ធ្ងរផងដែរលើសេរីភាពមូលដ្ឋានដូចជាការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម ដែលទាញការចាប់អារម្មណ៍យ៉ាងខ្លាំងពីសហគមន៍អន្តរជាតិមកលើប្រទេសកម្ពុជា ដោយសារការបង្ក្រាបរបស់រដ្ឋាភិបាលលើសកម្មជន អ្នកការពារសិទ្ធិមនុស្ស និងសំឡេងជំទាស់ដែលលើកឡើងពីបញ្ហាប្រឈមសាធារណៈតាមរយៈការអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេ។ រហូតមកទល់ពេលនេះ មនុស្សជាង ១២០ នាក់ត្រូវបានចាប់ខ្លួនដោយសារតែការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួន។

ឆ្នាំ២០២០ បានបង្ហាញនូវកំណើននៃការអនុវត្ត**សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី**របស់សាធារណជន។ ខណៈកម្មកររោងចក្រកំពុងរងផលប៉ះពាល់សេដ្ឋកិច្ចដោយសារឥទ្ធិពលនៃជំងឺកូវីដ-១៩ ក្នុងប្រទេសកម្មករជាច្រើនបានប្រមូលផ្តុំគ្នាតវ៉ាកាន់តែច្រើនឡើងៗនៅតាមផ្លូវ។ សហគមន៍ដែលរងផលប៉ះពាល់ដោយទំនាស់ដីធ្លីបានបន្តប្រមូលផ្តុំគ្នាដើម្បីស្វែងរកដំណោះស្រាយពីសំណាក់អាជ្ញាធរ រីឯក្រុមផ្នែកបរិស្ថានក៏បានតវ៉ាជំទាស់ទៅនឹងការលក់បឹងដែលនៅសេសសល់ចុងក្រោយមួយចំនួនក្នុងរាជធានីភ្នំពេញ។ ជាមួយគ្នាផងដែរមានក្រុមប្រជាពលរដ្ឋនានាបានតស៊ូមតិដើម្បីឱ្យមានការដោះលែងបុគ្គលមួយចំនួនដែលត្រូវបានឃុំខ្លួនក្រោមការចោទប្រកាន់ទាក់ទងនឹងករណីនយោបាយ។ ជាការគួរឱ្យបារម្ភខ្លាំង កំណើនក្នុងការជួបប្រជុំទាំងនេះបានជួបការរារាំង និងការរឹតត្បិតពីសំណាក់អាជ្ញាធរ ព្រមទាំងមានការចាប់ខ្លួនអ្នកតវ៉ាដោយសន្តិវិធីជាច្រើននាក់ផងដែរ។ នៅថ្ងៃទី៣១ ខែកក្កដា លោក រ៉ុង ឈុន មេដឹកនាំសហជីពត្រូវបានចាប់ខ្លួន ហើយបន្ទាប់មកមនុស្សជាង ១០ នាក់ ផ្សេងទៀតត្រូវបានដាក់ពន្ធនាគារដោយសារចូលរួមតវ៉ាឱ្យដោះលែងរូបលោក។ បន្ថែមពីនេះ ការប្រើប្រាស់កម្លាំង បង្ក្រាបរបស់អាជ្ញាធរទៅលើអ្នកតវ៉ាដោយសន្តិវិធីមានការកើនឡើង ដោយយ៉ាងតិចមាន ១៥ ករណី ក្នុងឆ្នាំ២០២០ ដែលបានរាយការណ៍។ ចំនួននេះបានកើនជិតទ្វេរដង បើប្រៀបធៀបទៅនឹងតួលេខដែលបានកត់ត្រាកាលពីឆ្នាំមុន។ ជាពិសេស សកម្មជនជាយុវជននិងអ្នកការពារសិទ្ធិមនុស្សជាស្ត្រីត្រូវប្រឈមនឹងការបង្ក្រាបទាំងនេះ។

**សេរីភាពក្នុងការបញ្ចេញមតិ** ក៏ទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរផងដែរក្នុងឆ្នាំ២០២០នេះ ដែលសកម្មភាពនៃការវាយប្រហារគឺផ្តោតទៅលើការបញ្ចេញមតិនៅលើប្រព័ន្ធអ៊ីនធឺណិត។ ដោយក្នុងនោះ បុគ្គលមួយចំនួនត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារ ដូចជា **សយ ស្រស់** កម្មការិនីរោងចក្រ និងជាសកម្មជនសហជីពដែលបានចែករំលែកសាររបស់នាងបង្ហាញពីកង្វល់ទាក់ទងនឹងសិទ្ធិការងារនៅលើបណ្តាញហ្វេសប៊ុក ហើយ **គា សុគុណ** និង **ឡុង ពុទ្ធារ៉ា** អ្នកចម្រៀងរ៉េប ដែលបង្ហោះបទចម្រៀងរបស់ខ្លួនលើបណ្តាញសង្គម។ សេរីភាពសារព័ត៌មានក៏មានការធ្លាក់ចុះផងដែរ ដោយមាននិន្នាការបង្ក្រាបលើអ្នកសារព័ត៌មានដូចជាការចាប់ខ្លួន និងការបិទអង្គភាពសារព័ត៌មានជាដើម។ អ្នកសារព័ត៌មានចំនួនបីរូបរួមមាន **សុវណ្ណ រិទ្ធី, សុខ ឧត្តម** និង **រស់ សុកេត** ត្រូវបានចាប់ខ្លួនក្នុងឆ្នាំនេះ និងរងការចោទប្រកាន់ពីបទញុះញង់ក្រោមមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌដោយសារការបំពេញវិជ្ជាជីវៈសារព័ត៌មានបែបស៊ើបអង្កេតស្របច្បាប់។ **រស់ សុកេត** និង **សុខ ឧត្តម** កំពុងស្ថិតក្នុងការឃុំខ្លួនហើយការ

ប្រកាសសាលក្រមលើ **សុខ ឧត្តម** ត្រូវបានលើកពេលដោយពុំមានការបញ្ជាក់កាលបរិច្ឆេទច្បាស់លាស់។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានដកហូតអាជ្ញាប័ណ្ណអង្គភាពព័ត៌មានចំនួន ៤ ផងដែរ ដោយអាជ្ញាប័ណ្ណចំនួន ៣ ក្នុងចំណោមនោះជាកម្មសិទ្ធិរបស់អ្នកដែលជាប់ឃុំទាំងបីនាក់ខាងលើ។

ជាចុងក្រោយ សេរីភាពក្នុងការចងក្រងសមាគមក្លាយជាគោលដៅនៃការបង្ក្រាបក្នុងឆ្នាំនេះ។ ក្រុមបរិស្ថានដូចជា បណ្តាញសហគមន៍ព្រៃឡង់ និងចលនាមាតាធម្មជាតិ ព្រមទាំងក្រុមសកម្មជនយុវជនក្នុងនោះរួមទាំង ខ្មែរថាវរៈ ត្រូវបានរារាំងសកម្មភាពជាញឹកញាប់ហើយសមាជិករបស់ពួកគេជាច្រើនរូបប្រឈមនឹងការចាប់ខ្លួននិងការឃាត់ឃាំងតាមប្រព័ន្ធតុលាការតាមរយៈការជួយសម្រួលពីអាជ្ញាធរ។ ក្រុមទាំងបីខាងលើនេះត្រូវបានរដ្ឋាភិបាលចាត់ទុកថាជាក្រុមខុសច្បាប់ ព្រោះពុំបានគោរពតាមលក្ខខណ្ឌនៃការចុះបញ្ជីដែលតម្រូវដោយច្បាប់ស្តីពី*សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល* ដែលជាការរំលោភលើសេរីភាពក្នុងការចងក្រងសមាគម។ ម្យ៉ាងទៀត នៅក្នុងឆ្នាំ២០២០ សមាជិកសហជីពរាប់ពាន់នាក់ប្រឈមមុខបាត់បង់ការងារ ដោយមានសេចក្តីរាយការណ៍ជាច្រើនលើកឡើងថានិយោជកបាននឹងកំពុងប្រើជំងឺកូវីដ-១៩ ជាលេសបិទបាំងការបញ្ឈប់សមាជិកសហជីពពីក្រុមហ៊ុនរបស់ពួកគេ។ សកម្មជនសហជីពជាច្រើននាក់បានប្រឈមនឹងការឃាត់ឃាំងដូចជា **ទូច កុសល** ប្រធានសហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជាបានទទួលលិខិតព្រមានលុបបញ្ជិកាជាច្រើនដងពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយសារការគាំទ្រឱ្យកម្មករធ្វើកូដកម្ម។ ជាងនេះទៀត នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ជាគម្រប់ខួប ៣ ឆ្នាំ ចាប់តាំងពីការរំលាយគណបក្សសង្គ្រោះជាតិ("គ.ស.ជ") មកបានបង្ហាញពីការធ្លាក់ចុះនៃលទ្ធិប្រជាធិតេយ្យនៅកម្ពុជា។ អតីតសមាជិក និងអ្នកគាំទ្រ គ.ស.ជ បន្តប្រឈមនឹងការឃាត់ឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើហិង្សា។ នៅក្នុងឆ្នាំ២០២០ មានការកោះហៅអតីតសមាជិក គ.ស.ជ ចំនួន ១៣៩ រូប ក្នុងទ្រង់ទ្រាយធំ ដើម្បីចូលរួមសវនាការនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ ទាក់ទងនឹងការចោទប្រកាន់ថា គ.ស.ជ. ប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាល និងមានករណីវាយប្រហារជាច្រើនហូរហែលើសមាជិក គ.ស.ជ ពីភាគីទី៣ ដែលភាគច្រើននៃករណីទាំងនោះនៅពុំទាន់មានការស៊ើបអង្កេតនៅឡើយ។

ជាការសោកស្តាយខ្លាំងដែលការរំលោភបំពានសិទ្ធិមនុស្សទាំងនេះពុំមែនជារឿងចម្លែក តែជាលំអានគួរឱ្យព្រួយបារម្ភនៅរយៈពេលពីរបីឆ្នាំចុងក្រោយនេះ។ ប្រការនេះមានឥទ្ធិពលប៉ះពាល់ធ្ងន់ធ្ងរដល់សង្គមកម្ពុជា ជាការបន្ទាបបង្អាក់បុគ្គលនានាក្នុងការចូលរួមកិច្ចការសាធារណៈ និងជំរុញឱ្យមានវប្បធម៌ភ័យខ្លាច ការជិនណាយក្នុងនយោបាយ និងការដាក់គំនាបខ្លួនឯង។ ដើម្បីឱ្យសង្គមមួយមានការអភិវឌ្ឍរីកចម្រើន និងមានសន្តិភាព ជាការចាំបាច់ដែលមនុស្សគ្រប់រូបអាចអនុវត្តសិទ្ធិសេរីភាពមូលដ្ឋានរបស់ខ្លួនដើម្បីចូលរួមក្នុងជីវភាពសាធារណៈ និងលទ្ធិប្រជាធិបតេយ្យ។

រដ្ឋាភិបាលត្រូវប្តេជ្ញាចិត្តក្នុងការលើកកម្ពស់សិទ្ធិមនុស្ស និងតម្លៃនៃលទ្ធិប្រជាធិបតេយ្យដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាស្នូលសិទ្ធិមនុស្សផ្សេងៗ ដែលខ្លឹមសារសំខាន់នៃលិខិតូបករណ៍ទាំងនេះមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ **នៅក្នុងឱកាសនៃទិវាសិទ្ធិមនុស្ស យើងខ្ញុំសូមអំពាវនាវឲ្យ រដ្ឋាភិបាលគោរពការប្តេជ្ញាចិត្តសិទ្ធិមនុស្សរបស់ខ្លួន ដោយបញ្ឈប់ជាបន្ទាន់នូវការបន្តការវាយប្រហារទៅលើសំឡេងជំទាស់ទាំងអស់នៅក្នុងប្រទេស និងដោះលែងបុគ្គលដែលត្រូវបានឃុំខ្លួនដោយសារការអនុវត្តសេរីភាព**

មូលដ្ឋានរបស់ពួកគេ។ យើងខ្ញុំក៏សូមស្នើយ៉ាងទទូចដល់រដ្ឋាភិបាលត្រូវតែធានាច្បាប់ថ្មីៗ និងច្បាប់កំពុងធរមាន ទាំងអស់អនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងបំពេញតាមកាតព្វកិច្ចសិទ្ធិមនុស្សដែលរដ្ឋាភិបាលបាន ប្តេជ្ញាក្នុងអំឡុងពេលការត្រួតពិនិត្យជាសកលតាមកាលកំណត់ (យូភីអ)។

- ចប់ –

អង្គការសង្គមស៊ីវិលដែលគាំទ្រសេចក្តីថ្លែងការណ៍នេះ រួមមាន៖

1 សម្ព័ន្ធគណនេយ្យភាពសង្គម កម្ពុជា (ANSA)
2 ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
3 សហជីពនិយោជិតទេសចរណ៍អាស៊ាននៃសណ្ឋាគារកាំបូឌីយ៉ាណា
4 សហជីពនិយោជិតទេសចរណ៍អាស៊ាន នៃសណ្ឋាគារ រ៉ាហ្វលឡឺរ៉ូយ៉ាល់
5 សហជីពនិយោជិតទេសចរណ៍អាស៊ាន នៃសណ្ឋាគារ សាន់ វេ ភ្នំពេញ
6 សហគមន៍បឹងទន្លេម្រេច ខេត្តព្រះវិហារ
7 សហគមន៍បឹងប្រាំ
8 សហគមន៍បឹងឈូក ភ្នំពេញ
9 សហគមន៍បុរីកីឡា ភ្នំពេញ
10 សហគមន៍ ប៊ូស្រា ខេត្តមណ្ឌលគិរី
11 អង្គការព្រះពុទ្ធសាសនាសម្រាប់សន្តិភាព (BPO)
12 សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជា (BWTUC)
13 អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
14 សហព័ន្ធសហជីពកម្ពុជា (CATU)
15 មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR)
16 សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CSFWF)
17 សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា អាដហុក (ADHOC)
18 មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
19 មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
20 សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា
21 អង្គការសម្ព័ន្ធភាពការពារសិទ្ធមនុស្សកម្ពុជា (CHRAC)
22 អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា
23 វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
24 សហភាពការងារកម្ពុជា (CLC)

25 សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)

26 សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (C.T.W.U.F)

27 បណ្តាញយុវជនកម្ពុជា (CYN)

28 សមាគមមន្ត្រីរាជការឯករាជ្យ (CICA)

29 មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស (CENTRAL)

30 សម្ព័ន្ធសហជីពសេរីស្ត្រីកាត់ដេរ (CFTUWT)

31 សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C.CAWDU)

32 សម្ព័ន្ធសមាគមន៍កសិករកម្ពុជា (CCFC)

33 គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)

34 អង្គការគណៈកម្មាធិការសហប្រត្តិបត្តិការដើម្បីកម្ពុជា (CCC)

35 អង្គការសមធម៌កម្ពុជា

36 សហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)

37 សហគមន៍បណ្តាញអតីតស្ត្រីបឹងកក់

38 សហព័ន្ធសហជីពសេរីឯករាជ្យ (FUFI)

39 អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា

40 សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)

41 សហព័ន្ធសហជីពឯករាជ្យ (INTUFE)

42 សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (KKKHRDA)

43 សហគមន៍កូនគ្រៀល ខេត្តឧត្តរមានជ័យ

44 សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (L.R.S.U)

45 សហគមន៍ដីធ្លីជីខក្រោម ភូមិព្រែកជីក ឃុំជីខក្រោម ខេត្តកោះកុង

46 សហគមន៍ដីធ្លីឡពាង ខេត្តកំពង់ឆ្នាំង

47 សហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា (NIFTUC)

48 សហគមន៍ការពារធនធានធម្មជាតិស្រុកក្រគរ ខេត្តពោធិសាត់

49 បណ្តាញអ្នកការពារព្រៃឡង់ ខេត្តកំពង់ធំ

50 សហគមន៍ដីធ្លីប៉ៃលិន ខេត្តប៉ៃលិន

51 អង្គការស្ពានសន្តិភាព

52 សហគមន៍ភ្នំបាត

53 សហគមន៍ភ្នំក្រោម ខេត្តសៀមរាប

54 សហគមន៍ភូមិ២៣ ភ្នំពេញ

55 សហគមន៍ព្រៃពាយ ខេត្តកំពត

56 សហគមន៍ឃុំប្រមេរ ខេត្តព្រះវិហារ

57 សហគមន៍ផ្លូវរថភ្លើងទួលសង្កែ A ភ្នំពេញ

58 អង្គការសមាគមជាងត្នោត (STT)

59 សហគមន៍ស្ពីក្រោមរហាលសួង ខេត្តបាត់ដំបង

60 សហគមន៍ SOS ព្រលានយន្តហោះអន្តរជាតិភ្នំពេញ

61 សហគមន៍តានី ១៩៧ ឃុំជីខលើ ខេត្តកោះកុង

62 វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

63 មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR)

64 សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម

65 សហគមន៍ថ្មដា ខេត្តពោធិសាត់

66 សហគមន៍ទួលសង្កែ B ភ្នំពេញ

67 អង្គការតម្លាភាពកម្ពុជា

68 អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង

69 អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន